# ពន្លឺបញ្ញា

(បទពាក្យ៧)

កណ្ដាលអធ្រាត្រផ្អៀតគយគន់ ធម្មជាតិយប់យន់ក្រោមដួងខែ
តារាលឹមៗតាមដង្ហែ អបអមកៀកក្បែរលើវេហាស៍។
ពន្លឺច័ន្ទ្រចាំងលើផែនដី ជួយជារស្មីដល់សត្តា
អោយបានសុខសាន្តនាលោកា បំបាត់ទុក្ខាក្នុងដួងចិត្ត។
អង្គនិសាករឈ្នះអន្ធការ ដោយរង្សីថ្លាត្រចង់ពិត
ទោះពពកខ្មៅនៅបាំងជិត ក៏មិនងងឹតស្លុបស្លុងបាន។
ច័ន្ទ្រអើយអ្នកដូចដួងបញ្ញា ស្ថិតក្នុងចិន្តាជនកល្យាណ
កបដោយមេត្តាដ៏ក្សេមក្សាន្ត ពុំដែលរំខានដល់អ្នកផង។
រស្មីដួងខែភ្លឺត្រជាក់ សព្វសត្វពឹងពាក់បំបាត់ហ្មង
ពន្លឺបញ្ញាថ្លាកន្លង អាចជួយចម្លងផុតទុក្ខភ័យ។
មានរូបមានរាងទៀងបញ្ញា កើតគ្រប់កាយាមិនរើសវ័យ
ឧបសគ្គចាក់ស្រេះកាយហឫទ័យ តាមផ្ចាញ់យកជ័យគ្រប់វេលា។
ពេលខ្សែជីវិតជួបអាសន្ន មិនអាចបែរបន់ព្រហ្មទេវា
គឺយកបញ្ញាមកជាគ្នា ដោះស្រាយវាងវៀរផុតភ្នក់កម្ម។
ចាស់ថាបញ្ញាជាអាវុធ មានមុខថ្លាមុតរាល់ខែឆ្នាំ
មិនចេះរេចរិលឬប្រេះស្រាំ យកទុកជាឆ្នាំចាំរូបកាយ។
ជីវិតរស់នៅដោយបញ្ញា នាំអោយភ្លឺថ្លាទូលាយឆ្ងាយ
ដោយចេះវិចារណ៍សព្វនាយអាយ មិនអោយឃ្លាតក្លាយខុសទំនង។
ភ្លឺទាំងថ្ងៃយប់គ្រប់កោះកៀន ផ្សាយសព្វវិញ្ញាណគ្មានរំលង
ធ្វើអ្វីលៃផុតភាពឆ្គាំឆ្គង មិនអោយចូលស៊ងការថ្លោះធ្លោយ។
អ្នកមានបញ្ញាថ្លាគំនិត តែងគិតមិនឈានក្រោយបង់បោយ
ជួយខ្លួនថែមជួយអ្នកខ្សត់ខ្សោយ បានរស់បានសោយសុខគ្រប់គ្នា។
ដួងច័ន្ទ្រភ្លឺថ្លាតែខាងខ្នើត បញ្ញាភ្លឺធើតគ្រប់វេលា
កើតមានបញ្ញាព្រោះវិជ្ជា សិក្សាមិនរាទើបសំរេច។✍


(០៩ មករា ២០០៣)

ភិក្ខុ វណ្ណគុត្តោ ស្វាត សាលឿម